# និន្នាការសេដ្ឋកិច្ចសង្គម

## Socio-Economic Trends

### ខែឧសភា-មិថុនា ឆ្នាំ២០១៩ /May-June 2019

## មាតិកា


| | ទំព័រ |
|---|---|
| **ខ្លឹមសារសង្ខេប/Executive summary** | **១** |
| **១. និន្នាការសេដ្ឋកិច្ចកម្ពុជា/Cambodia economic trends** | **៣** |
| ១.១. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់/Consumer price index | ៣ |
| ១.២. វិស័យហិរញ្ញវត្ថុ/Finance | ៤ |
| ១.៣. វិស័យពាណិជ្ជកម្ម/Trade | ៥ |
| ១.៤. ការអនុវត្តថវិកា/Budget execution | ៦ |
| ១.៥. វិស័យវិនិយោគឯកជន/Private investment | ៧ |
| ១.៦. វិស័យទេសចរណ៍/Tourism | ៨ |
| ១.៧. វិស័យសំណង់/Construction | ៩ |
| **២. និន្នាការថ្លៃទំនិញសំខាន់ៗលើទីផ្សារអន្តរជាតិ/International commodity prices** | **១១** |
| ២.១. ថ្លៃប្រេងឆៅ (Crude oil price: Brent, WTI, Dubai) | **១១** |
| **៣. ឧបសម្ព័ន្ធ** | **១៣** |

## ខ្លឹមសារសង្ខេប / Executive summary

**១.** នៅខែឧសភា ឆ្នាំ២០១៩នេះ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់និងសេវាកម្មនៅរាជធានីភ្នំពេញបានកើនឡើង ២,០% ធៀបនឹងឆ្នាំមុន។ កំណើននេះ គឺដោយសារការកើនឡើងនៃសន្ទស្សន៍ថ្លៃ ក្រុមភោជនីយដ្ឋាន ក្រុមភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ ក្រុមសម្លៀកបំពាក់និងស្បែកជើង និងក្រុមអាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង។ តាមការធ្វើចំណោលដល់ខែធ្នូ ឆ្នាំ២០១៩ អត្រាអតិផរណាប្រចាំឆ្នាំ (Year on Year) និងអតិផរណាមធ្យមប្រចាំឆ្នាំ (Year Average) អាចមានអត្រា ២,៩% និង ២,១% រៀងគ្នា។ អត្រានេះស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបាន ដោយសារថ្លៃម្ហូបអាហារមានស្ថិរភាព និងថ្លៃប្រេងសាំងមាននិន្នាការថមថយ ដែលជាបច្ច័យល្អដល់ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៅឆ្នាំ២០១៩។

**២.** គិតត្រឹមខែឧសភា ឆ្នាំ២០១៩ ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន **៩២,៦** ទ្រីលានរៀល ថយចុះ ២,១% ធៀបនឹងខែមុន ប៉ុន្តែកើនឡើង ២៧,៣% ធៀបនឹងឆ្នាំមុន ក្នុងនោះឥណទានតម្រូវការផ្ទាល់ខ្លួនមានចំនួន ១៧,៨ ទ្រីលានរៀល ថយចុះ១៤,៩% ធៀបនឹងខែមុន តែកើនឡើង ៤៤,៩% ធៀបនឹងឆ្នាំមុន។ តម្លៃប្រាក់រៀលបានបន្តថយចុះក្នុងខែមិថុនានេះ ដោយអត្រាប្តូរប្រាក់រៀលធៀបនឹងដុល្លារអាមេរិកស្មើនឹង ៤ ០៦៦ រៀល/ដុល្លារ ។ តម្លៃប្រាក់រៀលប្រែប្រួលបន្តិចបន្តួចជាលក្ខណៈរដូវកាល ដោយមាននិន្នាការថយចុះ បន្ទាប់ពីបុណ្យចូលឆ្នាំខ្មែររហូតដល់ខែកញ្ញា និងកើនឡើងមកវិញពីខែតុលាដល់ខែមីនានៃឆ្នាំបន្ទាប់។ រូបិយវត្ថុទូទៅM2មានចំនួន ៩៤,៩ ទ្រីលានរៀល បានកើនឡើង ០,៥% ធៀបនឹងខែមុន និងបានកើនឡើង ២១,៦% ធៀបនឹងឆ្នាំមុន។ ក្នុងរយៈពេល៦ខែ ឆ្នាំ២០១៩នេះ តម្លៃជួញដូរមូលបត្រកម្មសិទ្ធិសរុបមានចំនួន ១៣៦ ប៊ីលានរៀល បានកើនឡើង ៣១ដង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។

**៣.** តាមរយៈទិន្នន័យផ្លូវការពីអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា (admin data) **ស្ថានភាពនៃការនាំចេញរបស់កម្ពុជាក្នុងរយៈពេល ៥ខែដើមឆ្នាំ២០១៩នេះ នៅតែមានសន្ទុះល្អប្រសើរពោលគឺ ការនាំចេញមាន ទំហំទឹកប្រាក់សរុប ៥ ៣០៨ លានដុល្លារ (១៩,៨% បើធៀបនឹងផសស) កើនឡើង ១៥,៥% ធៀបនឹងក្នុងរយៈពេលដូចគ្នាឆ្នាំមុន។** កំណើននេះ បានមកពីការបន្តកំណើននាំចេញផលិតផលសំខាន់ៗ ជាពិសេសផលិតផលកាត់ដេរនិងស្បែកជើង (១៩,១%) និងអង្ករ (១៣,១%)។ **គិតត្រឹម ៥ខែ ឆ្នាំ២០១៩នេះ** ការនាំចូលមានទំហំទឹកប្រាក់សរុបចំនួន ៨ ២២៣ លានដុល្លារ (៣០,៧% បើធៀបនឹងផសស) បានកើនឡើង ២១,៥% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ កំណើននេះ បានមកពីការបន្តកំណើននាំចូលផលិតផលសំខាន់ៗ ជាពិសេសកំណើនខ្ពស់នៃការនាំចូលសម្ភារសំណង់ គ្រឿងយន្ត និងប្រេងឥន្ធនៈ។

**៤.** នៅខែមិថុនា ឆ្នាំ២០១៩ រដ្ឋបាលថ្នាក់ជាតិអនុវត្តចំណូលក្នុងស្រុកសរុបចំនួន **២ ០៧៣,៥** ប៊ីលានរៀល ឬស្មើនឹង **១០,៥%** នៃច្បាប់ឆ្នាំ២០១៩ កើនឡើង **៣៣,៩%** ធៀបនឹងខែមិថុនា ឆ្នាំ២០១៨ ដែលក្នុងនោះ មានចំណូលសារពើពន្ធ **១ ៧៤៥,២** ប៊ីលានរៀល និងចំណូលមិនមែនសារពើពន្ធ **៣០៧,២** ប៊ីលានរៀល។ រដ្ឋបាលថ្នាក់ជាតិក្នុងខែមិថុនានេះ បានអនុវត្តចំណាយសរុបចំនួន **១ ៥៧៦,១** ប៊ីលានរៀល ឬស្មើនឹង **៦,៤%** នៃច្បាប់ឆ្នាំ២០១៩ ថយចុះ **៤,៩%** បើធៀបនឹងខែមិថុនា ឆ្នាំ២០១៨។ **ជាលទ្ធផល គិតត្រឹមខែមិថុនា ឆ្នាំ២០១៩ តុល្យភាពថវិកាចរន្តមានអតិរេកសាច់ប្រាក់ចំនួន ៤ ៩៣១,១ ប៊ីលានរៀល និងតុល្យភាពថវិកាសរុបមានអតិរេកសាច់ប្រាក់**

**ចំនួន ២ ៥៩៨,៥ ប៊ីលានរៀល។ ជារួម ការប្រមូលចំណូលនៅតែបន្តកើនឡើង ដោយសារការខិតខំធ្វើកំណែទម្រង់ជាបន្តបន្ទាប់ តាមរយៈការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូល និងការអនុវត្តចំណាយដោយសន្សំសំចៃ និង ផ្អែកលើសមិទ្ធផលជាចំបង (Output-oriented)។**

**៥.** ក្នុងរយៈពេល ៦ខែ ដើមឆ្នាំ២០១៩នេះ គម្រោងវិនិយោគឯកជនសរុបដែលទទួលបានការអនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាមានចំនួន **១០០** គម្រោង មានទុនវិនិយោគប្រមាណ **៤ ៦២៣** លានដុល្លារអាមេរិក កើនឡើង **៣៥** គម្រោង និង ទុនវិនិយោគកើនឡើងជិត ២ដង ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ ក្នុងចំណោមគម្រោងទាំង ១០០ នេះ, ៨៥ គម្រោងត្រូវបានវិនិយោគក្នុងវិស័យឧស្សាហកម្ម, ១០ គម្រោងក្នុងវិស័យទេសចរណ៍, ៣ គម្រោងក្នុងវិស័យសេវាកម្ម និង ២ គម្រោងក្នុងវិស័យកសិកម្ម។ ***បើគិតពីទុនវិនិយោគ ៧៦,៦% នៃទុនវិនិយោគសរុប បានមកពីវិនិយោគិនកម្ពុជា ដោយសារការបោះទុនវិនិយោគយ៉ាងគំហុកក្នុងវិស័យទេសចរណ៍ (៨០% នៃទុនវិនិយោគសរុបរយៈពេល៦ខែនេះ)។ និន្នាការនេះ បង្ហាញពីវឌ្ឍនភាពនៃកំណើនសហគ្រិនភាពក្នុងស្រុក និង កំណើនវិនិយោគក្នុងវិស័យឧស្សាហកម្ម ដែលជាបច្ច័យក្នុងការបង្កើនល្បឿននៃឧស្សាហនីយកម្ម។***

**៦.** ក្នុងរយៈពេល ៥ខែ ឆ្នាំ២០១៩ នេះ ចំនួនភ្ញៀវទេសចរអន្តរជាតិសរុបមាន ២,៩ លាននាក់ បានកើនឡើង ១១,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន **ក្នុងនោះភ្ញៀវទេសចរចិន បានកើនឡើង ៤០% ឬបានចូលរួមកំណើន (contribution to growth) ១២,២% នៃកំណើនសរុប** ក្នុងខណៈដែល ភ្ញៀវទេសចរពីឡាវ ថៃ វៀតណាម ជប៉ុន បារាំង និងអង់គ្លេស មានកំណើនតិចតួច លើកលែងតែ កូរ៉េ អាមេរិក និង ប្រទេសផ្សេងទៀត ដែលមានកំណើនអវិជ្ជមាន។

**៧.** ក្នុងរយៈពេល ៦ខែ ដើមឆ្នាំ២០១៩នេះ សំណើសុំសាងសង់សរុបមានចំនួន **១ ៩៥២ គម្រោង កើនឡើង ៣០៥ គម្រោង** ***(កំណើនភាគច្រើនជាប្រភេទសំណង់លំនៅដ្ឋាន និងឧស្សាហកម្ម)*** ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន។ យោងតាមទិន្នន័យសំណង់ប្រភេទលំនៅដ្ឋានមាន ១ ៦៥៧ គម្រោង, សំណង់ប្រភេទពាណិជ្ជកម្មមាន ១១៧ គម្រោង, សំណង់ប្រភេទឧស្សាហកម្មមាន ៨១ គម្រោង, សំណង់ប្រភេទទេសចរណ៍មាន ៥០ គម្រោង, សំណង់ប្រភេទសាធារណៈ (មិនមែនថវិការដ្ឋ) មាន ៣៣ គម្រោង, និង សំណង់ប្រភេទវិនិយោគមាន ១៤ គម្រោង។ កំណើននៃគម្រោងសាងសង់នេះ បានបង្ហាញពីការបន្តកំណើនវិនិយោគលើវិស័យសំណង់និងតម្រូវការក្នុងស្រុកលើសំណង់លំនៅដ្ឋាន ពិសេសរាជធានីភ្នំពេញ និងខេត្តសៀមរាបក្នុងរយៈពេល៦ខែនេះ។

**៨.** ថ្លៃប្រេងឆៅ (Brent) លើទីផ្សារអន្តរជាតិក្នុងខែមិថុនា ឆ្នាំ២០១៩ ថ្លៃ ៦២,៩ដុល្លារ/បារ៉ែល បានថយចុះប្រមាណ ១០,៨% បើធៀបនឹងខែមុន និង ថយចុះប្រមាណ ១៦,៣% បើធៀបនឹងខែមិថុនាឆ្នាំមុន។

# ៣. ឧបសម្ព័ន្ធ

## ១. និន្នាការសេដ្ឋកិច្ចកម្ពុជា / Cambodia economic trends

### ១.១. ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ / Consumer price index

**តារាង ១.១ក៖ បម្រែបម្រួលសន្ទស្សន៍ថ្លៃនៃក្រុមទំនិញទាំង១២ (គិតជា%)**

| បរិយាយ | ២០១៩ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|
| | ធៀបនឹងខែមុន (MoM) | | | | ធៀបនឹងឆ្នាំមុន (YoY) | | | |
| | កុម្ភៈ | មីនា | មេសា | ឧសភា | កុម្ភៈ | មីនា | មេសា | ឧសភា |
| **មុខទំនិញគ្រប់មុខ** | 0.8 | 0.3 | 0.3 | 0.2 | 2.0 | 2.2 | 2.1 | 2.0 |
| ១-អាហារនិងភេសជ្ជៈមិនមានជាតិស្រវឹង | 0.7 | -0.1 | 0.6 | 0.3 | 2.2 | 1.9 | 1.9 | 1.9 |
| ២-ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | 0.3 | 0.1 | -0.1 | 0.0 | 6.4 | 6.7 | 5.0 | 5.4 |
| ៣-សម្លៀកបំពាក់និងស្បែកជើង | 0.9 | 0.2 | 0.2 | -0.6 | 3.6 | 3.6 | 3.4 | 3.0 |
| ៤-ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ននិងឥន្ធនៈដទៃទៀត | 0.8 | 0.6 | 0.1 | 0.1 | 1.2 | 1.9 | 1.9 | 1.8 |
| ៥-គ្រឿងសង្ហារឹម សម្ភារៈប្រើប្រាស់និងការថែទាំ | 0.3 | -0.2 | 0.1 | -0.7 | 1.6 | 1.7 | 1.5 | 0.7 |
| ៦-សុខាភិបាល | 0.2 | -0.2 | 0.0 | -0.1 | 2.3 | 1.9 | 1.5 | 1.4 |
| ៧-ការដឹកជញ្ជូន | 1.6 | 2.0 | 1.5 | 0.5 | -3.9 | -1.8 | -0.8 | -1.0 |
| ៨-គមនាគមន៍ | 0.1 | -0.2 | 1.5 | 0.4 | -0.4 | -0.4 | -0.6 | -0.2 |
| ៩-ការកំសាន្តនិងវប្បធម៌ | -0.1 | -0.3 | 0.1 | 0.0 | 0.9 | 0.8 | 0.6 | 0.9 |
| ១០-ការសិក្សា | 0.0 | 0.0 | 0.0 | 0.0 | 0.4 | 0.4 | 0.0 | 0.0 |
| ១១-ភោជនីយដ្ឋាន | 1.9 | 1.2 | -1.5 | 0.0 | 7.2 | 8.2 | 6.6 | 6.1 |
| ១២-ទំនិញនិងសេវាកម្មផ្សេងៗ | 1.1 | -0.1 | 0.1 | 0.0 | 1.3 | 1.4 | 1.1 | 1.0 |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិ (NIS)*

*សម្គាល់៖ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

**តារាង ១.១ខ៖ បម្រែបម្រួលសន្ទស្សន៍ថ្លៃម្ហូបអាហារមួយចំនួន (គិតជា%)**

| បរិយាយ | ២០១៩ | | | | ២០១៩ | | | |
|---|---|---|---|---|---|---|---|---|
| | ធៀបនឹងខែមុន (MoM) | | | | ធៀបនឹងឆ្នាំមុន (YoY) | | | |
| | កុម្ភៈ | មីនា | មេសា | ឧសភា | កុម្ភៈ | មីនា | មេសា | ឧសភា |
| អង្ករ | 0.6 | 0.0 | 0.4 | 0.8 | 2.9 | 2.7 | 3.0 | 3.6 |
| សាច់គោ | 0.2 | 0.0 | 0.2 | -0.1 | 1.6 | 1.7 | 1.1 | 0.5 |
| សាច់មាន់ | 0.0 | 0.5 | 0.3 | 0.1 | 2.9 | 4.2 | 3.5 | 3.3 |
| សាច់ទា | 0.6 | 0.0 | 0.4 | 0.9 | 3.0 | 3.1 | 3.0 | 4.0 |
| សាច់ជ្រូក | 0.6 | -0.6 | 2.1 | -0.8 | 2.0 | 0.8 | 2.4 | 1.6 |
| ត្រីទឹកសាប និងត្រីទឹកសមុទ្រ | 0.2 | 0.0 | 0.7 | 0.1 | 2.4 | 2.2 | 2.3 | 1.5 |
| ក្នុងនោះត្រីស្រស់ | 0.0 | 0.0 | 0.7 | 0.2 | 1.6 | 1.3 | 1.4 | 0.7 |
| ផ្លែឈើ | 1.3 | 0.2 | -0.3 | 1.2 | 1.2 | 1.4 | -0.6 | 1.3 |
| ផ្លែឈើស្រស់ | 1.4 | 0.4 | -0.4 | 1.4 | 1.2 | 1.6 | -0.8 | 1.4 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| បន្លែ | 1.4 | -0.6 | 1.1 | 1.3 | 3.9 | 3.0 | 2.7 | 3.2 |
| បន្លែជាស្លឹក | 1.4 | -0.4 | 0.9 | 0.2 | 6.5 | 5.2 | 4.7 | 3.9 |
| បន្លែជាផ្លែ | 2.2 | -1.1 | 2.3 | 3.1 | 3.8 | 2.2 | 2.6 | 5.5 |

*ប្រភព÷ វិទ្យាស្ថានជាតិស្ថិតិ (NIS)*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.២. វិស័យហិរញ្ញវត្ថុ / Finance

### ១.២.១. ផ្នែករូបិយវត្ថុនិងធនាគារ

**តារាង ១.២.១ក÷ ស្ថានភាពរូបិយវត្ថុក្នុងខែឧសភា ឆ្នាំ២០១៩ (ប៊ីលានរៀល, %)**

| សូចនាកររូបិយវត្ថុ | ២០០៥ | ២០១០ | ២០១៥ | ២០១៨ | ២០១៩ | | | Δ(%) | | |
|---|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | ធ្នូ | ធ្នូ | មីនា | មេសា | ឧសភា | ខែមុន | ១ឆ្នាំមុន | CAGR5 |
| **រូបិយវត្ថុទូទៅ M2** | **5,025** | **19,477** | **48,868** | **88,443** | **93,016** | **94,495** | **94,947** | **0.5%** | **21.6%** | **21.9%** |
| រូបិយវត្ថុក្រៅធនាគារជាតិ (៛) | 1,282 | 3,099 | 5,942 | 9,255 | 9,664 | 9,810 | 9,704 | -1.1% | 13.9% | 15.6% |
| ប្រាក់បញ្ញើចរន្ត (៛) | 41 | 122 | 844 | 971 | 1,118 | 1,151 | 1,383 | 20.2% | 29.9% | 18.0% |
| បញ្ញើមានកាលកំណត់និងសន្សំ (៛) | 113 | 408 | 1,550 | 3,209 | 2,660 | 2,776 | 3,095 | 11.5% | 33.0% | 27.7% |
| បញ្ញើជារូបិយប័ណ្ណបរទេស (FCD) | 3,589 | 15,848 | 40,532 | 75,008 | 78,704 | 80,758 | 80,764 | 0.01% | 22.0% | 22.7% |
| **អត្រា FCD / M2 (%)** | **71.4%** | **81.4%** | **83%** | **84.8%** | **85.4%** | **85.5%** | **85.1%** | -- | -- | -- |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

**តារាង ១.២.១ខ÷ ឥណទាន និងអត្រាការប្រាក់ផ្តល់ដោយធនាគារពាណិជ្ជ (ប៊ីលានរៀល, %)**

| សូចនាករ | ២០១០ | ២០១៥ | ២០១៨ | ២០១៩ | | | Δ(%) | | |
|---|---|---|---|---|---|---|---|---|---|
| | ធ្នូ | ធ្នូ | ធ្នូ | មីនា | មេសា | ឧសភា | ខែមុន | ១ឆ្នាំមុន | CAGR5 |
| **ឥណទានផ្តល់ដោយធនាគារពាណិជ្ជ** | **13,221** | **47,946** | **84,736** | **87,564** | **94,610** | **92,622** | **-2.1%** | **27.3%** | **23.2%** |
| ឥណទានផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុ | 177 | 1,169 | 3,014 | 2,973 | 3,378 | 3,598 | 6.5% | 47.5% | 45.0% |
| ឥណទានផ្តល់ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ | 11,695 | 39,807 | 64,979 | 67,337 | 69,307 | 70,246 | 1.4% | 23.0% | 20.4% |
| វិស័យសេវាកម្ម | 8,675 | 27,380 | 44,898 | 46,824 | 48,373 | 49,147 | 1.6% | 26.3% | 21.3% |
| វិស័យកសិកម្ម | 884 | 4,973 | 7,524 | 7,612 | 7,551 | 7,511 | -0.5% | 5.9% | 21.1% |
| វិស័យឧស្សាហកម្ម | 1,205 | 3,960 | 4,770 | 4,517 | 4,686 | 4,842 | 3.3% | 6.5% | 6.8% |
| វិស័យសំណង់ | 931 | 3,493 | 7,787 | 8,384 | 8,696 | 8,747 | 0.6% | 33.9% | 27.6% |
| ឥណទានតម្រូវការផ្ទាល់ខ្លួននិងផ្សេងៗ | 1,349 | 6,971 | 16,744 | 17,255 | 21,925 | 18,778 | -14.4% | 41.8% | 35.5% |
| ឥណទានតម្រូវការផ្ទាល់ខ្លួន | 1183 | 6110 | 15707 | 16301 | 20951 | 17829 | -14.9% | 44.9% | 40.4% |
| ឥណទានផ្សេងៗ | 166 | 861 | 1037 | 954 | 974 | 949 | -2.6% | 1.2% | 5.6% |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

| តារាង ១.២.១ត÷ ឥណទាន និងអត្រាការប្រាក់ផ្តល់ដោយធនាគារពាណិជ្ជ (ប៊ីលានរៀល, %) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ២០១០ | ២០១៥ | ២០១៨ | ២០១៩ | | | Δ(%) | | |
| | ធ្នូ | ធ្នូ | ធ្នូ | មីនា | មេសា | ឧសភា | ខែមុន | ១ឆ្នាំមុន | CAGR5 |
| **ឥណទានផ្តល់ដោយធនាគារពាណិជ្ជ** | **13,221** | **47,946** | **84,736** | **87,564** | **94,610** | **92,622** | **-2.1%** | **27.3%** | **23.2%** |
| ឥណទានផ្តល់ដល់គ្រឹះស្ថានហិរញ្ញវត្ថុ | 177 | 1,169 | 3,014 | 2,973 | 3,378 | 3,598 | 6.5% | 47.5% | 45.0% |
| ឥណទានផ្តល់ដល់គ្រឹះស្ថានមិនមែនហិរញ្ញវត្ថុ | 11,695 | 39,807 | 64,979 | 67,337 | 69,307 | 70,246 | 1.4% | 23.0% | 20.4% |
| វិស័យសេវាកម្ម | 8,675 | 27,380 | 44,898 | 46,824 | 48,373 | 49,147 | 1.6% | 26.3% | 21.3% |
| វិស័យកសិកម្ម | 884 | 4,973 | 7,524 | 7,612 | 7,551 | 7,511 | -0.5% | 5.9% | 21.1% |
| វិស័យឧស្សាហកម្ម | 1,205 | 3,960 | 4,770 | 4,517 | 4,686 | 4,842 | 3.3% | 6.5% | 6.8% |
| វិស័យសំណង់ | 931 | 3,493 | 7,787 | 8,384 | 8,696 | 8,747 | 0.6% | 33.9% | 27.6% |
| ឥណទានតម្រូវការផ្ទាល់ខ្លួននិងផ្សេងៗ | 1,349 | 6,971 | 16,744 | 17,255 | 21,925 | 18,778 | -14.4% | 41.8% | 35.5% |
| ឥណទានតម្រូវការផ្ទាល់ខ្លួន | 1183 | 6110 | 15707 | 16301 | 20951 | 17829 | -14.9% | 44.9% | 40.4% |
| ឥណទានផ្សេងៗ | 166 | 861 | 1037 | 954 | 974 | 949 | -2.6% | 1.2% | 5.6% |

*ប្រភព÷ ធនាគារជាតិនៃកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្នង់ និង (.) ស្មើក្បៀស*

## ១.២.២. ផ្នែកទីផ្សារមូលបត្រ

| តារាង ១.២.២ក÷ ការជួញដូរមូលបត្រកម្មសិទ្ធិលើទីផ្សារមូលបត្រកម្ពុជា (ពាន់ភាគហ៊ុន, លានរៀល) | | | | | | | |
|---|---|---|---|---|---|---|---|
| **សូចនាករ** | **២០១៥** | **២០១៦** | **២០១៧** | **២០១៨** | **៦ខែ២០១៩** | **ធៀប៦ខែឆ្នាំមុន** | **១៨/១៧/** |
| សន្ទស្សន៍ផ.ម.ក (គិតត្រឹមចុងគ្រា) | 399.10 | 356.31 | 344.56 | 489.35 | 619.27 | 83.6% | 42.0% |
| បរិមាណជួញដូរ (ពាន់ភាគហ៊ុន) | 1,422 | 2,614 | 3,624 | 3,781 | 14,021 | 1,319.4% | 4.4% |
| តម្លៃជួញដូរ (លានរៀល) | 7,040 | 10,024 | 12,570 | 24,902 | 136,237 | 3,134.3% | 98.1% |

*ប្រភព÷ ទីផ្សារមូលបត្រកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្នង់ និង (.) ស្មើក្បៀស*

| តារាង ១.២.២ខ÷ ព័ត៌មានមូលបត្រកម្មសិទ្ធិលើទីផ្សារមូលបត្រកម្ពុជា (រៀល, ភាគហ៊ុន) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ភាគហ៊ុនចុះបញ្ជី | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | មិថុនា-១៩ | ចំនួនភាគហ៊ុនចុះបញ្ជី | ចំនួនភាគហ៊ុនបោះផ្សាយ |
| តម្លៃបិទទីផ្សារ | | | | | | | | | |
| PPWSA | 5,360 | 4,400 | 5,080 | 4,100 | 3,860 | 4,200 | 6,000 | 86,973,162 | 13,045,975 |
| GTI | -- | 6,900 | 4,020 | 4,320 | 4,700 | 4,320 | 4,500 | 40,000,000 | 8,000,000 |
| PPAP | -- | -- | 5,500 | 5,300 | 5,140 | 7,680 | 9,320 | 20,684,365 | 4,136,873 |
| PPSP | -- | -- | -- | 2,860 | 2,820 | 2,900 | 2,750 | 57,875,000 | 15,575,000 |
| PAS | -- | -- | -- | -- | 5,100 | 10,100 | 13,860 | 85,771,967 | 21,442,992 |

*ប្រភព÷ ផ្សារមូលបត្រកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្នង់ និង (.) ស្មើក្បៀស*

| តារាង ១.២.២ឥ÷ ព័ត៌មានមូលបត្របំណុលលើទីផ្សារមូលបត្រកម្ពុជា | | | |
|---|---|---|---|
| សញ្ញាបណ្ណ | HKL21A | LOLC22A | LOLC22B |
| ទឹកប្រាក់ (លានរៀល) | 120,000 | 53,600 | 26,400 |
| ចំនួនសញ្ញាបណ្ណ (ចំនួន) | 1,200,000 | 536,000 | 264,000 |
| តម្លៃចារឹក (រៀល) | 100,000 | 100,000 | 100,000 |
| ឥណប្រតិទាន (ឆ្នាំ) | 3 | 3 | 3 |
| អត្រាការប្រាក់ | 8.50% | 8.00% | 9.00% |
| ថ្ងៃបោះផ្សាយ | ១៤-វិច្ឆិកា-២០១៨ | ២៦-មេសា-២០១៩ | ២៦-មេសា-២០១៩ |
| ថ្ងៃដល់ឥណប្រតិទាន | ១៤-វិច្ឆិកា-២០២១ | ២៦-មេសា-២០២២ | ២៦-មេសា-២០២២ |

*ប្រភព÷ ផ្សារមូលបត្រកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.៣. វិស័យពាណិជ្ជកម្ម / Trades

| តារាង ១.៣÷ ការនាំចូលនិងការនាំចេញតាមមុខទំនិញសំខាន់ៗក្នុងខែឧសភា ឆ្នាំ២០១៩ (លានដុល្លារ) | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ២០១៦ ១២ខែ | ២០១៧ ១២ខែ | ២០១៨ ១២ខែ | ២០១៩ | | | | Δ% | |
| | | | | មីនា | មេសា | ឧសភា | ៥ខែ | ខែមុន | ៥ខែឆ្នាំមុន |
| **តម្លៃនាំចូលសរុប (I)** | **12,243** | **13,615** | **16,876** | **1,620.8** | **1,726.3** | **1,908.4** | **8,222.8** | **10.6%** | **21.5%** |
| វាយនភណ្ឌ | 3,573 | 3,776 | 4,592 | 359.8 | 428.2 | 476.0 | 2,002.9 | **11.2%** | **3.3%** |
| បរិក្ខារសំណង់ | 551 | 621 | 953 | 96.7 | 117.1 | 168.1 | 589.2 | **43.6%** | **68.2%** |
| គ្រឿងយន្ត | 1,027 | 1,158 | 1,452 | 169.0 | 172.2 | 180.9 | 823.6 | **5.1%** | **44.9%** |
| ប្រេងឥន្ធនៈ | 1,276 | 887 | 1,124 | 150.7 | 148.2 | 148.5 | 720.0 | **0.2%** | **94.9%** |
| ផ្សេងៗ | 5,816 | 7,173 | 8,755 | 844.6 | 860.6 | 934.8 | 4,087.2 | **8.6%** | **15.5%** |
| **តម្លៃនាំចេញសរុប (II)** | **10,184** | **11,142** | **12,739** | **1,164.6** | **883.7** | **1,195.1** | **5,307.9** | **35.2%** | **15.5%** |
| វាយនភណ្ឌ និងស្បែកជើង | 7,449 | 8,020 | 9,507 | 885.6 | 633.3 | 903.7 | 4000.3 | **42.7%** | **19.1%** |
| អង្ករ | 301 | 329 | 414 | 46.2 | 26.6 | 24.0 | 173.0 | **-9.6%** | **13.1%** |
| កៅស៊ូ | 165 | 254 | 218 | 13.6 | 13.6 | 13.5 | 71.0 | **-0.8%** | **5.1%** |
| ផ្សេងៗ | 2,269 | 2,539 | 2,600 | 219.2 | 210.2 | 253.9 | 1063.6 | **20.8%** | **5.6%** |
| **តុល្យភាពពាណិជ្ជកម្ម (II - I)** | **-2,059** | **-2,473** | **-4,138** | **-456.2** | **-842.6** | **-713.3** | **-2,914.9** | **--** | **--** |

*ប្រភពទិន្នន័យ÷ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.៤. ស្ថានភាពការអនុវត្តថវិការដ្ឋ / Budget execution

**តារាង ១.៤÷ ការអនុវត្តចំណូលនិងចំណាយ (គិតជាប៊ីលានរៀល)**

| បរិយាយ | ២០១៩ ៦ខែ | ការអនុវត្ត ២០១៨ | | | ការអនុវត្ត ២០១៩ | | | Δ% | |
|---|---|---|---|---|---|---|---|---|---|
| | | មេសា | ឧសភា | មិថុនា | មេសា | ឧសភា | មិថុនា | ខែមិថុនា ឆ្នាំមុន | ៦ខែ ឆ្នាំមុន |
| **១. ចំណូលសរុប** | **11,414.18** | **1,957.82** | **1,574.75** | **1,548.05** | **2,279.99** | **1,961.56** | **2,073.49** | **33.9%** | **20.9%** |
| ១.១ ចំណូលចរន្ត | **11,353.45** | **1,928.98** | **1,574.75** | **1,531.45** | **2,271.11** | **1,961.44** | **2,052.42** | **34.0%** | **21.0%** |
| ចំណូលសារពើពន្ធ | **10,179.39** | 1,613.44 | 1,436.83 | 1,375.11 | 2,114.09 | 1,793.93 | 1,745.22 | **26.9%** | **21.0%** |
| ចំណូលមិនមែនសារពើពន្ធ | **1,174.06** | 315.54 | 137.91 | 156.34 | 157.02 | 167.50 | 307.20 | **96.5%** | **21.1%** |
| ១.២ ចំណូលមូលធន | **60.73** | **28.83** | **-** | **16.59** | **8.88** | **0.13** | **21.07** | **27.0%** | **4.2%** |
| **២. ចំណាយសរុប** | **8,815.69** | **1,503.44** | **1,546.00** | **1,656.76** | **1,664.19** | **1,690.51** | **1,576.12** | **-4.9%** | **6.3%** |
| ២.១ ចំណាយចរន្ត | **6,422.35** | **943.16** | **1,143.58** | **1,101.71** | **1,239.13** | **1,215.48** | **1,269.65** | **15.2%** | **7.8%** |
| ចំណាយបៀវត្ស | **3,634.22** | 566.57 | 650.99 | 693.53 | 688.26 | 619.72 | 654.88 | **-5.6%** | **-1.0%** |
| ចំណាយមិនមែនបៀវត្ស | **2,788.13** | 376.59 | 492.59 | 408.18 | 550.87 | 595.76 | 614.76 | **50.6%** | **21.9%** |
| ២.២ ចំណាយមូលធន | **2,393.33** | **560.28** | **402.42** | **555.05** | **425.06** | **475.03** | **306.47** | **-44.8%** | **2.7%** |
| ការកែតម្រូវចំណាយ | - | - | - | - | - | - | - | | |
| **តុល្យភាពចរន្ត (សាច់ប្រាក់)** | **4,931.09** | **985.82** | **431.17** | **429.75** | **1,031.99** | **745.95** | **782.77** | | |
| **តុល្យភាពទូទៅ (សាច់ប្រាក់)** | **2,598.49** | **454.38** | **28.74** | **(108.72)** | **615.80** | **271.05** | **497.37** | | |

*ប្រភពទិន្នន័យ÷ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.៥. ស្ថានភាពវិនិយោគ / Investment

**តារាង ១.៥÷ ស្ថានភាពវិនិយោគក្នុងខែមិថុនា ឆ្នាំ២០១៩**

| សូចនាករ | ឯកតា | ២០១៥ ១២ខែ | ២០១៦ ១២ខែ | ២០១៧ ១២ខែ | ២០១៨ ១២ខែ | ២០១៩ | | | | Δ% | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | មេសា | ឧសភា | មិថុនា | ៦ខែ | ខែមុន | ៦ខែឆ្នាំមុន |
| ចំនួនគម្រោង | គម្រោង | 124 | 121 | 117 | 148 | 13 | 5 | 19 | 100 | **14** | **35** |
| ចំនួនទុនវិនិយោគ | លាន($) | 3,919 | 3,249 | 5,217 | 5,804 | 1,647 | 39 | 1,001 | 4,623 | **2,471%** | **59.7%** |
| ចំនួនការងារបង្កើត | ពាន់នាក់ | 144 | 127 | 137 | 178 | 17 | 8 | 23 | 141 | **135%** | **83.7%** |

*ប្រភព÷ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

*សម្គាល់÷ ១)*គិតជាចំនួនគម្រោង ២)ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.៦. ស្ថានភាពទេសចរណ៍ / Tourism

| តារាង ១.៦÷ ចំនួនភ្ញៀវអន្តរជាតិក្នុងខែឧសភា ឆ្នាំ២០១៩ (ពាន់នាក់) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | ២០១៥<br>១២ខែ | ២០១៦<br>១២ខែ | ២០១៧<br>១២ខែ | ២០១៨<br>១២ខែ | ២០១៩ | | | | Δ% | |
| | | | | | មីនា | មេសា | ឧសភា | ៥ខែ | ខែមុន | ៥ខែឆ្នាំមុន |
| **សរុប** | **4,775** | **5,012** | **5,602** | **6,201** | **633** | **538** | **473** | **2,888** | **-12%** | **11.4%** |
| **តាមអាកាស** | **2,476** | **2,704** | **3,313** | **4,097** | **456** | **377** | **343** | **2,019** | **-9%** | **16.9%** |
| ច្រកអន្តរជាតិភ្នំពេញ | 1,061 | 1,164 | 1,410 | 1,924 | 215 | 177 | 165 | 924 | **-7%** | **17.6%** |
| ច្រកសៀមរាប | 1,415 | 1,507 | 1,821 | 1,940 | 183 | 146 | 116 | 846 | **-21%** | **-4.5%** |
| ច្រកកងកេង | - | 33 | 82 | 234 | 58 | 54 | 62 | 249 | **15%** | **344.9%** |
| **តាមផ្លូវគោកនិងទឹក** | **2,299** | **2,307** | **2,289** | **2,104** | **177** | **161** | **130** | **870** | **-19%** | **0.3%** |
| ផ្លូវគោក | 2,151 | 2,154 | 2,144 | 1,960 | 156 | 147 | 126 | 786 | **-14%** | **-1.1%** |
| ផ្លូវទឹក | 148 | 153 | 145 | 144 | 21 | 13 | 4 | 84 | **-71%** | **15.4%** |

*ប្រភព÷ ក្រសួងទេសចរណ៍*

*សម្គាល់÷ ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ១.៧. ស្ថានភាពសំណង់ / Construction

| តារាង ១.៧÷ ស្ថានភាពសំណង់ក្នុងខែ ឧសភា ឆ្នាំ២០១៩ | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| សូចនាករ | ឯកតា | ២០១៥<br>១២ខែ | ២០១៦<br>១២ខែ | ២០១៧<br>១២ខែ | ២០១៨<br>១២ខែ | ២០១៩ | | | | Δ % | |
| | | | | | | មេសា | ឧសភា | មិថុនា | ៦ខែ | ខែមុន | ៦ខែឆ្នាំ |
| សរុបចំនួន | ចំនួន | 2,070 | 2,636 | 3,418 | 3,294 | 336 | 287 | 340 | 1,952 | **53***| **305*** |
| សរុបជាផ្ទៃក្រឡា | ពាន់ម២ | 7,766 | 12,158 | 11,382 | 12,569 | 1,900 | 300 | 993 | 6,948 | **230.5%** | **29.8%** |
| សរុបជាទឹកប្រាក់ | លាន($) | 3,335 | 5,580 | 6,799 | 5,755 | 1,041 | 152 | 498 | 3,370 | **227.6%** | **56.5%** |

*ប្រភព÷ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

*សម្គាល់÷ ១)*គិតជាចំនួនគម្រោង ២)ក្នុងតារាង (,) ស្មើកាត់ខ្ទង់ និង (.) ស្មើក្បៀស*

## ២. និន្នាការថ្លៃទំនិញសំខាន់ៗលើពិភពលោក / International commodity prices

| តារាង២÷ស្ថានភាពថ្លៃទំនិញសំខាន់ៗ (ថ្លៃមធ្យមប្រចាំខែ) | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| សូចនាករសំខាន់ៗ | | ឯកតា | ២០១៨ | | | ២០១៩ | | | △ផលធៀបជាភាគរយ | |
| | | | មីនា | មេសា | ឧសភា | មីនា | មេសា | ឧសភា | ខែមុន | ឆ្នាំមុន |
| ក្នុងស្រុក | សាំងស៊ូពែរ (EA 95) | រៀល/ លីត្រ | 4,163 | 4,275 | 4,525 | 3,975 | 4,150 | 4,275 | 3.01% | -5.52% |
| | សាំងធម្មតា (EA 92) | រៀល/ លីត្រ | 3,863 | 3,975 | 4,175 | 3,575 | 3,775 | 3,875 | 2.65% | -7.19% |
| | ម៉ាស៊ូត (DO 0.05%) | រៀល/ លីត្រ | 3,613 | 3,800 | 4,000 | 3,550 | 3,575 | 3,675 | 2.80% | -8.13% |
| | ហ្គាស | រៀល/១៥គ.ក្រ | 64,000 | 64,000 | 64,000 | 65,083 | 64,360 | 64,320 | -0.06% | 0.50% |
| | អង្ករកម្ពុជា (លេខ១) | រៀល/ គ.ក្រ | 2,660 | 2,680 | 2,670 | 3,635 | 3,680 | 3,680 | 0.00% | 37.83% |
| | អង្ករកម្ពុជា (លេខ២) | រៀល/ គ.ក្រ | 2,240 | 2,210 | 2,190 | 2,260 | 2,240 | 2,240 | 0.00% | 2.28% |
| | ម្រេច | រៀល/ គ.ក្រ | 36,250 | 32,200 | 27,800 | 29,100 | 30,250 | 28,950 | -4.30% | 4.14% |
| | កៅស៊ូគ្រួសារ (ជ័រស្ងួត) | រៀល/ គ.ក្រ | 4,475 | 4,388 | 4,520 | - | 4,320 | 4,200 | -2.78% | -7.08% |
| អន្តរជាតិ | Average Oil Price | ដុល្លារ/ បារ៉ែល | $64.17 | $68.79 | $73.43 | $63.79 | $68.58 | $66.83 | -2.55% | -8.99% |
| | Brent | ដុល្លារ/ បារ៉ែល | $66.45 | $71.63 | $76.65 | $66.41 | $71.20 | $70.53 | -0.94% | -7.98% |
| | Dubai | ដុល្លារ/ បារ៉ែល | $63.29 | $68.43 | $73.66 | $66.80 | $70.66 | $69.13 | -2.17% | -6.15% |
| | WTI | ដុល្លារ/ បារ៉ែល | $62.76 | $66.32 | $69.98 | $58.15 | $63.87 | $60.84 | -4.74% | -13.06% |
| | សាំងធម្មតា (US) | ដុល្លារ/ លីត្រ | $0.72 | $0.76 | $0.79 | $0.69 | $0.77 | $0.78 | 1.28% | -1.36% |
| | អង្ករថៃ (5%) | ដុល្លារ/ តោន | $430 | $451 | $451 | $406 | $413 | $409 | -0.97% | -9.31% |
| | អង្ករវៀតណាម (5%) | ដុល្លារ/ តោន | $410 | $413 | $419 | $343 | $341 | $351 | 2.88% | -16.24% |
| | អង្ករថៃ (25%) | ដុល្លារ/ តោន | $418 | $436 | $436 | $399 | $404 | $401 | -0.74% | -8.03% |
| | អង្ករថៃ A.1 (100%) | ដុល្លារ/ តោន | $404 | $430 | $432 | $382 | $391 | $387 | -1.16% | -10.42% |
| | កៅស៊ូ (TSR20) | ដុល្លារ/ តោន | $1,486 | $1,423 | $1,446 | $1,533 | $1,563 | $1,587 | 1.59% | 9.82% |
| | កៅស៊ូ (RSS3) | ដុល្លារ/ តោន | $1,740 | $1,723 | $1,751 | $1,747 | $1,762 | $1,795 | 1.83% | 2.46% |

*ប្រភព÷ ក្រសួងពាណិជ្ជកម្ម, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, World Bank, Association of Natural Rubber Producing Countries, Global Rubber Market (Asia Market), សហព័ន្ធស្រូវអង្ករកម្ពុជា, Mekong Oryza, General Directorate of Rubber, etc.*

**<u>កំណត់សម្គាល់</u>**

កៅស៊ូ÷

- កៅស៊ូ TSR20: ឬហៅថាកៅស៊ូស្ដង់ដារលេខ២០ រួមមានកៅស៊ូ SIR20, SMR20 និងSTR20 គឺសំដៅលើកៅស៊ូធម្មជាតិដែលមានសារធាតុផ្សេងៗទៀត២០%។ កៅស៊ូធម្មជាតិមានច្រើនប្រភេទ ក្នុងនោះកៅស៊ូដែលមានតម្រូវការប្រើប្រាស់ច្រើនជាងគេគឺកៅស៊ូស្ដង់ដារ (កៅស៊ូដុំ) និងកៅស៊ូបន្ទះ។ កៅស៊ូ TSR20 ជាប្រភេទកៅស៊ូដែលបានកែច្នៃក្នុងកម្រិតខ្ពស់ ប្រើប្រាស់សម្រាប់ ផលិតកម្មកង់ឡាន បំពង់ទីបជ័រ កម្រាលជ័រ ស្បែកជើងនិងអាវភ្លៀងជាដើម។ កៅស៊ូប្រភេទនេះមានកម្រិតស្អិតទាប ហើយងាយលាយបញ្ចូល ជាមួយសារធាតុដទៃ ដែលធ្វើឱ្យផលិតផលផលិតចេញពីកៅស៊ូនេះមានភាពរឹងមាំ ធន់និងមិនងាយសឹករិចរិល។ ប្រទេសសំខាន់ៗដែលផលិតកៅស៊ូប្រភេទនេះគឺម៉ាឡេស៊ី ថៃ ឥណ្ឌូណេស៊ី វៀតណាម និងចិន។
- កៅស៊ូRSS (Ribbed Smoked Sheets) បែងចែកជា៦ប្រភេទគឺ ប្រភេទលេខ 1, 2, 3, 4, 5 និងប្រភេទពិសេស មានពណ៌លឿង និងវេចខ្ចប់ជាបន្ទះ។ កៅស៊ូប្រភេទ RSS3 ច្រើនផលិតនៅប្រទេសថៃ ឥណ្ឌា និងឥណ្ឌូណេស៊ី ប្រើប្រាស់ជាវត្ថុធាតុ សម្រាប់ផលិតសំបកកង់រថយន្ត បំពង់ទីបជ័រ និងស្បែកជើង។ កៅស៊ូប្រភេទនេះប្រើប្រាស់ក្នុងឧស្សាហកម្មផលិតសំបកកង់ រថយន្ត និងដែលជាធាតុផ្សំលើស 50% នៃផលិតផល។

ប្រេងឆៅ÷

ប្រេងឆៅ Brent, WTI និង Dubai ជាប្រភេទប្រេងឆៅធុនស្រាល (Light Crude Oil) ដែលមានការទិញលក់ច្រើនជាងគេ និងជាថ្លៃមូលដ្ឋានក្នុងការទិញលក់កិច្ចសន្យាអនាគត (Future Contract)។ ប្រេងឆៅលើទីផ្សារអន្តរជាតិមានលក្ខណៈខុសគ្នា ទៅតាមប្រភេទដូចជា÷ ប្រភេទប្រេង Brent ច្រើនផលិតនៅតំបន់សមុទ្រអាត្លង់ទិចខាងជើង, ប្រភេទប្រេងរបស់អាមេរិក WTI (West Texas Intermediate) និងប្រភេទប្រេងរបស់អារ៉ាប់ប៊ីសាអ៊ូឌីត Dubai។ ប្រភេទប្រេងឆៅទាំងបីមានលក្ខណៈ ខុសគ្នាទៅតាមកម្រិតភាពស្រាល ហើយប្រភេទប្រេងឆៅដែលមានភាពស្រាលជាងគេអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។ API Gravity ត្រូវបានគេប្រើប្រាស់វាស់វែងភាពស្រាលនៃប្រភេទប្រេងឆៅនីមួយៗ។ ប្រភេទប្រេងដែលមានកម្រិត API Gravity កាន់តែខ្ពស់គឺជាប្រភេទប្រេងដែលកាន់តែស្រាល និងអាចចម្រាញ់ជាប្រេងឥន្ធនៈបានច្រើន។

- WTI 40o API
- Brent 38o API
- Dubai 32o API

រៀបចំដោយ

នាយកដ្ឋានស្ថិតិនិងវិភាគសេដ្ឋកិច្ច

អគ្គនាយកដ្ឋានគោលនយោបាយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ព័ត៌មានផ្សេងៗ សូមទាក់ទងក្រុមការងារ

ទូរស័ព្ទលេខ÷ ០២៣ ៤២៧ ៩១៣, ០៩៨  ២២ ៨៤ ៩៤

ម៉ោងធ្វើការ÷ ៧:០០ ដល់ ១១:០០ព្រឹក និង ២:០០ ដល់ ៥:០០រសៀល